# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងអប់រំ យុវជន និងកីឡា

# ក្របខ័ណ្ឌកម្មវិធីសិក្សា

## ថ្នាក់បណ្ឌិតអប់រំ
## ជំនាញអភិវឌ្ឍកម្មវិធីសិក្សានិងវិធីសាស្ត្រ
## បង្រៀន

វិទ្យាស្ថានជាតិអប់រំ ឆ្នាំ២០២០

# បុព្វកថា

ការកសាងសមត្ថភាព និងការអភិវឌ្ឍមូលធនមនុស្សឱ្យមានគុណភាព ភាពឆ្លើយតប និងសីលធម៌រស់នៅល្អ គឺជាអាទិភាពទី១ និងជាគោលដៅគន្លឹះ ដែលរាជរដ្ឋាភិបាលនីតិកាលទី៦ បាននិងកំពុងអនុវត្តតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤។

ដើម្បីរួមចំណែកក្នុងការសម្រេចឱ្យបានយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣ និងបានដាក់ចេញនូវគោលនយោបាយអប់រំចំនួន២ កម្មវិធីកំណែទម្រង់ចំនួន១៥ ដោយឈរលើសសរស្តម្ភចំនួន០៥។

ក្របខ័ណ្ឌកម្មវិធីសិក្សាថ្នាក់បណ្ឌិតអប់រំនេះត្រូវបានបង្កើតឡើងក្នុងគោលបំណងពីរគឺ៖ (១) ផ្នែកវិធីសាស្ត្របង្រៀន៖ ផ្តល់នូវខ្លឹមសារគន្លឹះសំខាន់ៗដល់អ្នកសិក្សា ស្តីពីវិធីសាស្ត្រ និងបច្ចេកទេស ក្នុងការបង្រៀន និងរៀននាសតវត្សទី២១ ដូចជាគោលវិធីសិស្សមជ្ឈមណ្ឌល វិធីបង្រៀននិងរៀនតាមបែបវិទ្យាសាស្ត្រ តាមបែបរិះរក តាមបែបដោះស្រាយបញ្ហា តាមបែបបញ្ញត្តិ តាមបែបសហការ តាមបែប៥Es តាមបែបប្លូម និងតាមវិធីផ្សេងៗទៀតដែលសមស្របនឹងស្ថានភាព និងបរិបទជាក់ស្តែង។ អ្នកសិក្សានឹងមានឱកាសអភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួន តាមរយៈការដកស្រង់បទពិសោធន៍ពីការសង្កេតថ្នាក់រៀន និងការសិក្សាមេរៀនតាមវីដេអូ ហើយពិភាក្សារកចំណុចខ្លាំង និងចំណុចកែលម្អមេរៀននោះ និង (២) ផ្នែកអភិវឌ្ឍកម្មវិធីសិក្សា៖ ផ្តល់ឱ្យអ្នកសិក្សា យល់ដឹងពីនិយមន័យកម្មវិធីសិក្សា គោលការណ៍រៀននិងបង្រៀន ជំហានក្នុងការអភិវឌ្ឍកម្មវិធីសិក្សា ចំនួនមុខវិជ្ជាដែលត្រូវបង្រៀនតាមកម្រិតថ្នាក់នីមួយៗ របាយម៉ោងសិក្សា និងស្តង់ដាចំណេះដឹង ជំនាញ និងឥរិយាបថ។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹម និងមានជំនឿយ៉ាងមុតមាំថាក្របខ័ណ្ឌកម្មវិធីសិក្សាថ្នាក់បណ្ឌិតអប់រំ ជំនាញការអភិវឌ្ឍកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀននេះ នឹងជួយលើកកម្ពស់សមត្ថភាពអ្នកសិក្សា ឱ្យបានយល់ដឹងកាន់តែច្បាស់ថែមទៀតពីវិធី វិធីសាស្ត្រ ល្បិច ស្នៀតក្នុងការបង្រៀន ការគ្រប់គ្រងថ្នាក់រៀន ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ចេះរៀបចំកម្មវិធីសិក្សាស្របតាមបរិបទកម្ពុជា និងចេះវិភាគស៊ីជម្រៅ ទៅលើកត្តាដែលជះឥទ្ធិពលដល់ការរៀន និងបង្រៀន។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណ និងកោតសរសើរចំពោះស្នាដៃដ៏ល្អ របស់ក្រុមការងារដែលបានខិតខំអភិវឌ្ឍក្របខ័ណ្ឌកម្មវិធីសិក្សានេះឡើង។

ថ្ងៃ [illegible] ខែ[illegible] ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

# គណៈកម្មការ

## I. គណៈកម្មការគ្រប់គ្រង

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិតសភាចារ្យ | ហង់ជួន ណារ៉ុន | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា |
| ២. ឯកឧត្តមបណ្ឌិតសភាចារ្យ | ណាត ប៊ុនរឿន | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |
| ៣. ឯកឧត្តម | យក់ ង៉ុយ | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |
| ៤. ឯកឧត្តម | ម៉ក់ ងយ | អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា |
| ៥. លោកជំទាវ | ឃួន វិច្ឆិកា | អគ្គនាយករងនៃអគ្គនាយកដ្ឋានអប់រំ |

## II. គណៈកម្មការរៀបរៀង និងចងក្រង

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | នាយកវិទ្យាស្ថានជាតិអប់រំ |
| ២. លោកបណ្ឌិត | នូវ វីរ៉ា | នាយករងវិទ្យាស្ថានជាតិអប់រំ |
| ៣. លោកបណ្ឌិត | ហុង គឹមជាង | នាយកវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ |
| ៤. លោកបណ្ឌិត | សុខ សូត្រ | ព្រឹទ្ធបុរសមហាវិទ្យាល័យអប់រំនៃស.ភ.ភ.ព |
| ៥. លោកបណ្ឌិត | ឈូក ច័ន្ទឆាយា | អនុប្រធាននា.បណ្តុះបណ្តាលនិងវិក្រឹតការ |
| ៦. លោកបណ្ឌិត | រ័ត្ន ឆាង | អគ្គលេខាធិការរងនៃគ.ទ.ក |
| ៧. ឯកឧត្តម | ទេព ភិយ្យោរិទ្ធ | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ |
| ៨. លោកបណ្ឌិត | ហ៊ាត់ ប៊ុនហេ | នាយករងវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ |
| ៩. លោកបណ្ឌិត | ហេង គ្រេង | ប្រធាននាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ |
| ១០. លោកបណ្ឌិត | ម៉ម សុជាតិ | សាស្ត្រាចារ្យស.ភ.ភ.ព |
| ១១. លោក | ម៉ន មុនិន្ទ | ប្រធានដេប៉ាតឺម៉ង់គ្រប់គ្រងនិងផែនការ |
| ១២. លោក | ចាប រតនា | អនុប្រ.ដេប៉ាតឺម៉ង់គ្រប់គ្រងនិងផែនការ |
| ១៣. លោកបណ្ឌិត | ឈាង សង្វាត | គ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ |
| ១៤. លោកបណ្ឌិត | អាន រ៉ូប្រាវ | គ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ |
| ១៥. កញ្ញា | ហ៊ សុីរី | ប្រធានការិ.នៃវិ.បច្ចេកវិទ្យាកំពង់ស្ពឺ |
| ១៦. កញ្ញា | ជិត ចាន់វន្ទី | អនុប្រធានលេខាធិការដ្ឋាននៃអគ្គ.អប់រំ |
| ១៧. លោក | ម៉ែន សំណាង | មន្ត្រីលេខាធិការដ្ឋាននៃអគ្គ.អប់រំ |

## III. គណៈកម្មការត្រួតពិនិត្យ និងកែលម្អ

| | | |
|---|---|---|
| ១. លោក | លឹម វ៉ាន់ | អនុប្រ.ដេប៉ាតឺម៉ង់ វដអ |
| ២. លោក | លន លីណា | មន្ត្រីដេប៉ាតឺម៉ង់ វដអ |
| ៣. លោកស្រី | សុខ វណ្ណា | មន្ត្រីដេប៉ាតឺម៉ង់ វដអ |
| ៤. លោក | ចាន់ ធឿន | មន្ត្រីដេប៉ាតឺម៉ង់ វដអ |
| ៥. លោក | ម៉ែន សុខសុន្ទី | មន្ត្រីដេប៉ាតឺម៉ង់ វដអ |

# មាតិកា

**បុព្វកថា** ...................................................... i
**គណៈកម្មការ** ...................................................... ii
**មាតិកា** ...................................................... iii
**ជំពូកទី១៖ ព័ត៌មានទូទៅ** ...................................................... 1
១.១- សេចក្តីផ្តើម ...................................................... 1
១.២- ឈ្មោះកម្មវិធីសិក្សា ...................................................... 1
១.៣- ចក្ខុវិស័យ ...................................................... 2
១.៤- គោលបំណង ...................................................... 2
១.៥- លទ្ធផលសិក្សារំពឹងទុក ...................................................... 2
១.៦- សមត្ថភាពវិជ្ជាជីវៈរំពឹងទុក ...................................................... 3
១.៧- អាជីពរំពឹងទុក ...................................................... 3
**ជំពូកទី២៖ សេចក្តីលម្អិតកម្មវិធីសិក្សា** ...................................................... 4
២.១- ប្រភេទកម្មវិធីសិក្សានិងចំនួនក្រេឌីត ...................................................... 4
២.២- រចនាសម្ព័ន្ធកម្មវិធីសិក្សា ...................................................... 4
២.៣- លក្ខខណ្ឌនៃការជ្រើសរើសចូលរៀន ...................................................... 5
២.៤- មុខវិជ្ជាក្នុងកម្មវិធីសិក្សា ...................................................... 6
២.៥- ការប្រឡងវាស់ស្ទង់គុណសម្បត្តិ ...................................................... 7
២.៦- ផែនការដំណើរការកម្មវិធីសិក្សា ...................................................... 8
**ជំពូកទី៣៖ សាស្ត្រាចារ្យ គម្រោងស្រាវជ្រាវ និក្ខេបបទ និងការវាយតម្លៃ** ...... 12
៣.១- សាស្ត្រាចារ្យបង្រៀនមុខវិជ្ជា ...................................................... 12
៣.២- សាស្ត្រាចារ្យណែនាំគោលនិងសាស្ត្រាចារ្យណែនាំរង ...................................................... 12
៣.៣- ការស្នើគម្រោងស្រាវជ្រាវសរសេរនិក្ខេបបទ ...................................................... 12
៣.៤- ការវាយតម្លៃការសិក្សា ...................................................... 13
៣.៥- ចំណាត់ថ្នាក់ពិន្ទុ ...................................................... 13
៣.៦- លទ្ធផលនៃការសិក្សា វិធីសាស្ត្របង្រៀន និងវិធីសាស្ត្រវាយតម្លៃ ...................................................... 14
**ជំពូកទី៤៖ ពណ៌នាមុខវិជ្ជា** ...................................................... 16
៤.១ ការពិពណ៌នាមុខវិជ្ជា ...................................................... 16
**ឯកសារយោង៖** ...................................................... 20
**ឧបសម្ព័ន្ធ៖ អត្ថន័យលេខកូដមុខវិជ្ជា** ...................................................... 21

# ជំពូកទី១៖
# ព័ត៌មានទូទៅ

## ១.១- សេចក្តីផ្តើម

កម្ពុជាគឺជាប្រទេសមួយដែលមានអរិយធម៌ឧត្តុងឧត្តម កិត្យានុភាពខ្ពង់ខ្ពស់ និងការរស់នៅរបស់ប្រជាជនប្រកបដោយភាពថ្លៃថ្នូរនិងស៊ីវិល័យ ក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន។ ជាក់ស្តែងនៅចន្លោះឆ្នាំ១៩៥០ និង ១៩៦០ ប្រទេសកម្ពុជាមានការអភិវឌ្ឍខ្លាំងទាំងផ្នែកសង្គមនិងសេដ្ឋកិច្ច ហើយវិស័យអប់រំត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយនៅក្នុងតំបន់និងនៅលើពិភពលោក។ ប៉ុន្តែក្នុងរយៈពេលពីរបីទសវត្សចុងក្រោយនេះ កម្ពុជាបានឆ្លងកាត់ទុក្ខសោកវិនាសអន្តរាយ និងទ្រុឌទ្រោមគួរឱ្យសោកស្តាយ។ នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ប្រព័ន្ធអប់រំត្រូវបានគេបោះបង់និងលុបបំបាត់ចោលទាំងស្រុង ហើយគ្រូបង្រៀនប្រមាណ ៨០ភាគរយត្រូវរងការកាប់សម្លាប់ ធ្វើឱ្យប្រទេសនេះបាត់បង់នូវធនធានមនុស្សប្រកបដោយសក្តានុពលជាច្រើន។

ស្ថិតក្នុងបរិបទនេះ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ សំដៅលើការបង្កើនគុណភាពធនធានមនុស្ស ជាពិសេសការបន្តពង្រឹងសមត្ថភាពនិងអភិបាលកិច្ចរបស់បុគ្គលិក និងគណៈគ្រប់គ្រងនៃស្ថាប័នដែលខ្លួនទទួលខុសត្រូវទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ ជាមួយគ្នានេះដែរ ក្រសួងអប់រំ យុវជន និងកីឡា បានខិតខំស្តារនិងអភិវឌ្ឍវិស័យអប់រំ ធ្វើឱ្យវិស័យនេះមានការរីកចម្រើនគួរឱ្យកត់សម្គាល់ សំដៅសម្រេចឱ្យបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា។ ក្រសួងបានធ្វើកំណែទម្រង់លើវិស័យអប់រំ ដោយបានរៀបចំនិងដាក់ឱ្យអនុវត្តនូវគោលនយោបាយអប់រំជាតិនិងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដើម្បីជានាបាននូវការលើកកម្ពស់គុណភាពនិងសេវាកម្មអប់រំប្រកបដោយគុណភាពនិងសមត្ថភាព ព្រមទាំងស័ក្តិសិទ្ធិភាពនៃបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ ដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការក្នុងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ដែលជាកត្តាគន្លឹះមិនអាចខ្វះបានក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ និងភាពប្រកួតប្រជែងរបស់ប្រទេសក្នុងពេលបច្ចុប្បន្ននិងសម្រាប់អនាគតរយៈពេលវែង។ ដើម្បីសម្រេចគោលដៅ កម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀនដើរតួយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលធនធានប្រកបដោយគុណភាព។

ឆ្លើយតបទៅនឹងតម្រូវការចាំបាច់ក្នុងការរៀបចំកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀន ក្រសួងអប់រំ យុវជន និងកីឡា បានលើកទឹកចិត្តនិងប្រគល់ភារកិច្ចឱ្យវិទ្យាស្ថានជាតិអប់រំ បើកដំណើរការកម្មវិធីសិក្សាថ្នាក់បណ្ឌិតអប់រំ ជំនាញកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀន ដោយមានការជួយឧបត្ថម្ភទាំងផ្នែកបច្ចេកទេស សម្ភារៈ និងថវិកា ពីរាជរដ្ឋាភិបាលនិង ដៃគូអភិវឌ្ឍនានា។ ការដាក់ឱ្យអនុវត្តកម្មវិធីសិក្សានេះ នឹងជួយឱ្យមន្ត្រីអប់រំថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិទាំងអស់ដែលកំពុងបម្រើការងារក្នុងវិស័យអប់រំ មានឱកាសលើកកម្ពស់សមត្ថភាពរបស់ខ្លួននៅក្នុងការបំពេញការងារឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត។

## ១.២- ឈ្មោះកម្មវិធីសិក្សា

ភាសាខ្មែរ៖ បណ្ឌិតអប់រំ ជំនាញកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀន

ភាសាអង់គ្លេស៖ Doctor of Philosophy in Curriculum and Instruction

## ១.៣- ចក្ខុវិស័យ

កម្មវិធីសិក្សាថ្នាក់បណ្ឌិតអប់រំ ជំនាញកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀន បណ្តុះបណ្តាលធនធានមនុស្សផ្នែកស្រាវជ្រាវ និងអភិវឌ្ឍកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀន ប្រកបដោយឧត្តមភាពនិងវិជ្ជាជីវៈសម្រាប់ការអប់រំសតវត្សទី២១។

## ១.៤- គោលបំណង

កម្មវិធីសិក្សាថ្នាក់បណ្ឌិតអប់រំ ជំនាញកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀន មានគោលបំណងបណ្តុះបណ្តាលអ្នកសិក្សាឱ្យក្លាយជា៖

- អ្នកស្រាវជ្រាវនិងអភិវឌ្ឍកម្មវិធីសិក្សា រួមមានការអភិវឌ្ឍ ការអនុវត្ត និងការវាយតម្លៃកម្មវិធីសិក្សា ប្រកបដោយសមត្ថភាពនិងក្រមសីលធម៌វិជ្ជាជីវៈ
- អ្នកស្រាវជ្រាវនិងអភិវឌ្ឍផ្នែកវិធីសាស្ត្របង្រៀន រួមមានការអភិវឌ្ឍ ការអនុវត្តការវាយតម្លៃការបង្រៀន ប្រកបដោយសមត្ថភាពនិងក្រមសីលធម៌វិជ្ជាជីវៈ។

## ១.៥- លទ្ធផលសិក្សារំពឹងទុក

អ្នកសិក្សាដែលបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតអប់រំ ជំនាញកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀនប្រកបដោយជោគជ័យ គឺជាបុគ្គលដែលមានគុណតម្លៃសម្រាប់សង្គមជាតិនិងពិភពលោក។ អ្នកសិក្សាត្រូវមានសម្បទាស្របតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិ (ឆ្នាំ២០១៤) រួមមានចំណេះដឹង ជំនាញការគិតវិភាគ ជំនាញទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ និងជំនាញលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង។

### ១.៥.១- ចំណេះដឹង

យល់ដឹងពីចំណុចសំខាន់ៗស្តីពីកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀន រួមមាន៖

- ទស្សនវិជ្ជា ចិត្តវិទ្យា ទ្រឹស្តី គោលការណ៍ និងទស្សនាទាននៃកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀន ជាមូលដ្ឋានគ្រប់កម្រិតថ្នាក់
- យល់ដឹងច្បាស់អំពីទស្សនវិជ្ជាអប់រំ ចិត្តវិទ្យាអប់រំ ប្រវត្តិអប់រំ ច្បាប់អប់រំ មូលដ្ឋានសង្គមនៃការអប់រំ និងការវិវត្តចុងក្រោយនៃការអប់រំជាពិសេសផ្នែកកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀននៅគ្រប់កម្រិតថ្នាក់
- យល់ដឹងពីការអភិវឌ្ឍជំនាញកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀនដែលមានឥទ្ធិពលទៅលើការអនុវត្តវិជ្ជាជីវៈក្នុងវិស័យអប់រំ។

### ១.៥.២- ជំនាញការគិតវិភាគ

- ស្រាវជ្រាវលើការងារផ្នែកកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀន ដើម្បីបង្កើតចំណេះដឹងថ្មីៗនិងដោះស្រាយបញ្ហាផ្សេងៗក្នុងការងារអភិវឌ្ឍ អនុវត្ត និងវាយតម្លៃកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀនគ្រប់កម្រិតថ្នាក់ប្រកបដោយគំនិតច្នៃប្រឌិតនិងនិរន្តរភាព តាមរយៈការសិក្សាពេញមួយជីវិត
- វិភាគនិងសំយោគទ្រឹស្តី ទស្សនាទាន យុទ្ធសាស្ត្រ និងគោលនយោបាយនានា មកជាកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀនសម្រាប់អនុវត្តក្នុងវិស័យអប់រំគ្រប់កម្រិតសិក្សាប្រកបដោយភាពទន់ភ្លន់និងប្រសិទ្ធភាពខ្ពស់ ស្របតាមទិសដៅអប់រំជាតិ តំបន់ និងសកល។

### ១.៥.៣- ជំនាញទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ

- ប្រព្រឹត្តយ៉ាងសមស្របប្រកបដោយស្វ័យភាពនិងការផ្តួចផ្តើមគំនិតកម្រិតខ្ពស់ក្នុងសកម្មភាពទាក់ទងការរៀបចំកម្មវិធីសិក្សានិងវិធីសាស្រ្តបង្រៀន
- សម្របសម្រួលនិងលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងការធ្វើការងារជាក្រុម និងអនុវត្តយ៉ាងមានប្រសិទ្ធភាពក្នុងភាពជាអ្នកដឹកនាំក្នុងវិជ្ជាជីវៈផ្នែកកម្មវិធីសិក្សានិងវិធីសាស្រ្តបង្រៀនដ៏ស្មុគស្មាញ
- ស្រាវជ្រាវនិងស្វែងរកឫសគល់នៃបញ្ហាទាក់ទងនឹងកម្មវិធីសិក្សានិងវិធីសាស្រ្តបង្រៀន ដើម្បីរកដំណោះស្រាយប្រកបដោយសុក្រិតនិច្ច័យនិងឈរលើប្រយោជន៍រួមជាមូលដ្ឋាន។

### ១.៥.៤- ជំនាញលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង

- ប្រើប្រាស់ភាសាខ្មែរនិងភាសាបរទេស និងបច្ចេកវិទ្យាក្នុងការងារទំនាក់ទំនង ការស្វែងរកព័ត៌មានផ្នែកកម្មវិធីសិក្សានិងវិធីសាស្រ្តបង្រៀន ការរៀបចំសិក្ខាសាលា ការរៀបចំគម្រោង ការសរសេររបាយការណ៍ ការធ្វើបទបង្ហាញ ការបោះពុម្ពផ្សាយក្នុងទម្រង់ជានិក្ខេបបទជំនាញ ឬរបាយការណ៍គម្រោងស្តីពីបញ្ហាសំខាន់និងស្មុគស្មាញណាមួយប្រកបដោយតម្លាភាពនិងការទទួលខុសត្រូវខ្ពស់
- ប្រើប្រាស់និងវិភាគព័ត៌មាន ទិន្នន័យ គណិតវិទ្យា និងស្ថិតិ យ៉ាងមានប្រសិទ្ធភាព។

## ១.៦- សមត្ថភាពវិជ្ជាជីវៈរំពឹងទុក

អ្នកសិក្សាដែលបំពេញគ្រប់លក្ខខណ្ឌនៃកម្មវិធីសិក្សាថ្នាក់បណ្ឌិតអប់រំ ជំនាញកម្មវិធីសិក្សានិងវិធីសាស្រ្តបង្រៀនដោយជោគជ័យ នឹងមានសមត្ថភាពវិជ្ជាជីវៈដូចខាងក្រោម៖

- ស្រាវជ្រាវដើម្បីរៀបចំបង្កើត កែលម្អ អនុវត្ត និងវាយតម្លៃកម្មវិធីសិក្សានិងវិធីសាស្រ្តបង្រៀន
- បង្កើតនិងដឹកនាំឱ្យមាននវានុវត្តន៍និងគំនិតច្នៃប្រឌិតផ្នែកកម្មវិធីសិក្សានិងវិធីសាស្រ្តបង្រៀនស្របតាមការវិវត្តក្នុងបរិបទជាតិ តំបន់ និងសកល
- វិភាគស៊ីជម្រៅនិងស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមនានាទាក់ទងនឹងកម្មវិធីសិក្សានិងវិធីសាស្រ្តបង្រៀន
- ស្រាវជ្រាវចែករំលែក និងបង្រៀនជំនាញកម្មវិធីសិក្សានិងវិធីសាស្រ្តបង្រៀន និងមុខវិជ្ជាជំនាញពាក់ព័ន្ធ។

## ១.៧- អាជីពរំពឹងទុក

- អ្នកជំនាញរៀបចំ អភិវឌ្ឍ អនុវត្ត និងវាយតម្លៃកម្មវិធីសិក្សានិងវិធីសាស្រ្តបង្រៀនគ្រប់កម្រិតថ្នាក់
- អ្នកបណ្តុះបណ្តាល គ្រូឧទ្ទេស ផ្នែកកម្មវិធីសិក្សានិងវិធីសាស្រ្តបង្រៀន
- អ្នកស្រាវជ្រាវផ្នែកកម្មវិធីសិក្សានិងវិធីសាស្រ្តបង្រៀន
- សាស្រ្តាចារ្យជំនាញតាមគ្រឹះស្ថានឧត្តមសិក្សា។

# ជំពូកទី២៖
# សេចក្តីលម្អិតកម្មវិធីសិក្សា

## ២.១- ប្រភេទកម្មវិធីសិក្សានិងចំនួនក្រេឌីត

កម្មវិធីសិក្សាថ្នាក់បណ្ឌិតអប់រំ ជំនាញកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀនមានពីរប្រភេទ។ អ្នកសិក្សាអាចជ្រើសរើសប្រភេទណាមួយនៃកម្មវិធីសិក្សាដូចខាងក្រោម៖

ប្រភេទ១ ជាកម្មវិធីសិក្សាបែបស្រាវជ្រាវនិងសរសេរនិក្ខេបបទសុទ្ធសាធ។ អ្នកសិក្សាត្រូវចុះឈ្មោះចូលរៀនមុខវិជ្ជាបំពេញបន្ថែមចំនួនយ៉ាងតិច១២ក្រេឌីត។ ចំនួនក្រេឌីតសរុបមានចំនួន៥៧ក្រេឌីត។

ប្រភេទ២ ជាកម្មវិធីសិក្សាបែបរៀនមុខវិជ្ជានិងសរសេរនិក្ខេបបទ។ អ្នកសិក្សាត្រូវចុះឈ្មោះចូលរៀនតាមកម្មវិធីដែលបានកំណត់ រួមមានមុខវិជ្ជាបំពេញបន្ថែម មុខវិជ្ជារួមនៃឯកទេស មុខវិជ្ជាស្នូលនៃឯកទេស មុខវិជ្ជាតម្រង់ទិស មុខវិជ្ជាតម្រូវ[1] និងនិក្ខេបបទ។ ចំនួនក្រេឌីតសរុបមានចំនួន៥៧ក្រេឌីត។

## ២.២- រចនាសម្ព័ន្ធកម្មវិធីសិក្សា

| ល.រ. | ក្រុមមុខវិជ្ជា | ចំនួនក្រេឌីត | |
|---|---|---|---|
| | | ប្រភេទ១ | ប្រភេទ២ |
| 1 | មុខវិជ្ជាបំពេញបន្ថែម | 12 | 6 |
| 2 | មុខវិជ្ជាកម្រិតបណ្ឌិត(មុខវិជ្ជារួមនៃឯកទេស) | — | 3 |
| 3 | មុខវិជ្ជាកម្រិតបណ្ឌិត(មុខវិជ្ជាស្នូលនៃឯកទេស) | — | 6 |
| 4 | មុខវិជ្ជាតម្រង់ទិស | — | 9 |
| 5 | ការពារគម្រោងអត្ថបទស្រាវជ្រាវពិស្តារ | 3 | 3 |
| 6 | ការចុះផ្សាយអត្ថបទស្រាវជ្រាវកម្រិតជាតិឬកម្រិតអន្តរជាតិ * | 12 | 6 |
| 7 | ការចូលរួមវេទិកាវិទ្យាសាស្ត្រពាក់ព័ន្ធ | 6 | 3 |
| 8 | ការធ្វើសិក្ខាសាលាផ្ទាល់ខ្លួន * * | 6 | 3 |
| 9 | និក្ខេបបទ | 18 | 18 |
| | **សរុប** | 57 | 57 |
| | *អត្ថបទស្រាវជ្រាវចំនួន២ច្បាប់(១ច្បាប់ចំនួន៣ក្រេឌីត) សម្រាប់ការចុះឈ្មោះចូលរៀនប្រភេទ២<br>* * ចំនួន២ដង | | |

[1] មុខវិជ្ជាតម្រូវ(ពុំផ្តល់ក្រេឌីត)

## ២.៣- លក្ខខណ្ឌនៃការជ្រើសរើសចូលរៀន

ការដាក់ពាក្យចូលសិក្សាថ្នាក់បណ្ឌិតអប់រំ ជំនាញកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀន អ្នកសិក្សាត្រូវបំពេញលក្ខខណ្ឌចូលរៀនគ្រប់ចំណុចដែលបានកំណត់ដោយគណៈកម្មការគ្រប់គ្រងកម្មវិធីសិក្សាដូចខាងក្រោម៖

### ២.៣.១- កម្មវិធីសិក្សាប្រភេទទី១

- ក្នុងរយៈពេល៥ឆ្នាំចុងក្រោយ ត្រូវមានស្នាដៃបោះពុម្ពយ៉ាងតិចចំនួន២អត្ថបទ នៅក្នុងព្រឹត្តិបត្រឬទស្សនាវដ្ដីស្រាវជ្រាវ( Peer Review Journals )
- មានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ឬសញ្ញាបត្រសមមូល ដោយសរសេរសារណាពីគ្រឹះស្ថានឧត្តមសិក្សាដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា និងមានពិន្ទុសិក្សាសរុប( GPA ) មិនតិចជាង៣.០០ នៃប្រព័ន្ធ៤.០០ ឬមធ្យមភាគសមមូល( ៧០%ឡើង )
- មានសំណើគម្រោងស្រាវជ្រាវបឋម
- មានបទពិសោធលើការងារស្រាវជ្រាវផ្នែកអប់រំយ៉ាងតិច២ឆ្នាំ ឬបទពិសោធក្នុងការងារអប់រំយ៉ាងតិច៥ឆ្នាំ
- មានសមត្ថភាពភាសាអង់គ្លេសកំណត់ដោយកម្មវិធីIELTS ពិន្ទុ៥.០ ឬសមមូល ឬភាសាបារាំងកំណត់កម្រិត DELF B2 ឬតេស្តTCF ឬជាប់ការប្រឡងវាស់សមត្ថភាពដែលរៀបចំដោយវិទ្យាស្ថានជាតិអប់រំ
- មានសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា
- មានលក្ខណៈសម្បត្តិបន្ថែមផ្សេងៗទៀតដែលកំណត់ដោយគណៈកម្មការជ្រើសរើសនិស្សិតចូលសិក្សា។

### ២.៣.២- កម្មវិធីសិក្សាប្រភេទទី២

- មានបរិញ្ញាបត្រជាន់ខ្ពស់ឬសញ្ញាបត្រសមមូល ពីគ្រឹះស្ថានឧត្តមសិក្សាដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា និងមានពិន្ទុសិក្សាសរុប( GPA ) មិនតិចជាង២.៥០[2] នៃប្រព័ន្ធ៤.០០ ឬមធ្យមភាគសមមូល( ៦៥%ឡើង )
- មានសំណើគម្រោងស្រាវជ្រាវបឋម
- មានសមត្ថភាពភាសាអង់គ្លេសកំណត់ដោយកម្មវិធីIELTS ពិន្ទុ5.0 ឬសមមូល ឬភាសាបារាំងកំណត់កម្រិត DELF B2 ឬតេស្តTCF ឬជាប់ការប្រឡងវាស់សម្ថភាពដែលរៀបចំដោយវិទ្យាស្ថានជាតិអប់រំ
- មានសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា
- មានលក្ខណៈសម្បត្តិបន្ថែមផ្សេងៗទៀតដែលកំណត់ដោយគណៈកម្មការជ្រើសរើសនិស្សិតចូលសិក្សា។

---

[2] GPA ២.៥០ នៃប្រព័ន្ធ៤.០០ ប្រើសម្រាប់ការអនុវត្តសាកល្បង( Try Out )នៃក្របខណ្ឌកម្មវិធីសិក្សាថ្នាក់បណ្ឌិតអប់រំ ជំនាញអភិវឌ្ឍកម្មវិធីសិក្សានិងវិធី សាស្ត្របង្រៀន។ ពិន្ទុ( GPA ) ត្រូវមិនតិចជាង៣.០០ នៃប្រព័ន្ធ៤.០០ សម្រាប់ការអនុវត្តផ្លូវការនៃក្របខណ្ឌកម្មវិធីសិក្សានេះ។

## ២.៤- មុខវិជ្ជាក្នុងកម្មវិធីសិក្សា

### ២.៤.១- កម្មវិធីសិក្សាប្រភេទ១

#### ២.៤.១.១- មុខវិជ្ជាបំពេញបន្ថែម(ចំនួន១២ក្រេឌីត)

| | | | |
|---|---|---|---|
| 1. | ១០២២៥១ | ការរៀបចំនិងអភិវឌ្ឍវិធីសាស្ត្របង្រៀន<br>Instructional System Development and Implementation | ៣(៣-០-៩) |
| | ១០២២៥២ | ការរៀបចំនិងអភិវឌ្ឍកម្មវិធីសិក្សា<br>Advanced Curriculum and Implementation | ៣(៣-០-៩) |
| 2. | ១០២៣០១ | គំរូនៃការអនុវត្តកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀន<br>Implementation model of curriculum and instruction | ៣(៣-០-៩) |
| | ១០២២០១ | វិធីសាស្ត្រស្រាវជ្រាវអប់រំ | ៣(៣-០-៩) |

#### ២.៤.១.២- ការសរសេរនិងការពារនិក្ខេបបទ(ចំនួន៤៥ក្រេឌីត)

| | | | |
|---|---|---|---|
| 1. | ១០២៥៣១ | ការពារគម្រោងអត្ថបទស្រាវជ្រាវពិស្តារ | ៣ ក្រេឌីត |
| 2. | ១០២៥៣២ | ការចុះផ្សាយអត្ថបទស្រាវជ្រាវកម្រិតជាតិឬកម្រិតអន្តរជាតិ | ១២ ក្រេឌីត |
| 3. | ១០២៥៣៣ | ការចូលរួមវេទិកាវិទ្យាសាស្ត្រពាក់ព័ន្ធ | ៦ ក្រេឌីត |
| 4. | ១០២៥៣៤ | ការធ្វើសិក្ខាសាលាផ្ទាល់ខ្លួន | ៦ ក្រេឌីត |
| 5. | ១០២៥០១ | និក្ខេបបទ១(ប្រភេទ១) | ៣ ក្រេឌីត |
| 6. | ១០២៥០២ | និក្ខេបបទ២(ប្រភេទ១) | ៣ ក្រេឌីត |
| 7. | ១០២៥០៣ | និក្ខេបបទ៣(ប្រភេទ១) | ៣ ក្រេឌីត |
| 8. | ១០២៥០៤ | និក្ខេបបទ៤(ប្រភេទ១) | ៣ ក្រេឌីត |
| 9. | ១០២៥០៥ | និក្ខេបបទ៥(ប្រភេទ១) | ៣ ក្រេឌីត |
| 10. | ១០២៥០៦ | និក្ខេបបទ៦(ប្រភេទ១) | ៣ ក្រេឌីត |

### ២.៤.២- កម្មវិធីសិក្សាប្រភេទ២

#### ២.៤.២.១- មុខវិជ្ជាមូលដ្ឋានគ្រឹះបំពេញបន្ថែម(ចំនួន៦ក្រេឌីត)

| | | | |
|---|---|---|---|
| 1. | ១០២១០១ | ទ្រឹស្តីនិងនិន្នាការនៃការអប់រំ<br>Theory and Trends in education | ២(២-០-៦) |
| 2. | ១០២១០២ | បរិបទនៃការអប់រំតាមបែបឌីជីថល<br>Contemporary of digital education | ២(២-០-៦) |
| 3. | ១០២១០៣ | ចិត្តវិទ្យាអប់រំ Psychology of Education | ២(២-០-៦) |

#### ២.៤.២.២- មុខវិជ្ជាកម្រិតបណ្ឌិត រួមនៃឯកទេស(ចំនួន៣ក្រេឌីត)

| | | | |
|---|---|---|---|
| 1. | ១០២២០១ | វិធីសាស្ត្រស្រាវជ្រាវអប់រំ[3] | ៣(៣-០-៩) |

#### ២.៤.២.៣.មុខវិជ្ជាកម្រិតបណ្ឌិត ស្នូលនៃឯកទេស(ចំនួន៦ក្រេឌីត)

| | | | |
|---|---|---|---|
| 1. | ១០២២៥១ | ការរៀបចំនិងអភិវឌ្ឍវិធីសាស្ត្របង្រៀន<br>Instructional System Development and Implementation | ៣(២-២-៨) |

[3] មុខវិជ្ជានេះត្រូវរួមបញ្ចូលការសិក្សាស្តីពីស្ថិតិសម្រាប់ការស្រាវជ្រាវអប់រំ។

| | | | |
|---|---|---|---|
| | ១០២២៥២ | ការរៀបចំនិងអភិវឌ្ឍកម្មវិធីសិក្សា | ៣(២-២-៨) |
| | | Advanced Curriculum and Implementation | |

**២.៤.២.៤- មុខវិជ្ជាតម្រង់ទិសនិងការប្រឡងទូទៅ(ចំនួន៩ក្រេឌីត)**

| | | | |
|---|---|---|---|
| 1. | ១០២៣០១ | គំរូនៃការអនុវត្តកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀន[4] | |
| | | Implementation model of curriculum and instruction | ៣(៣-០-៩) |
| 2. | ១០២៣០១ | ការអប់រំគ្រូនិងគុណភាពគ្រូបង្រៀន | ២(២-០-៦) |
| 3. | ១០២៣០៣ | ភាពបន្សុីគ្នានៃការអប់រំការច្នៃប្រឌិត | ២(២-០-៦) |
| 4. | ១០២៣០៤ | ការវិភាគនិងការវាយតម្លៃលទ្ធផលរំពឹងទុកនៃកម្មវិធីសិក្សា | ២(២-០-៦) |

**២.៤.២.៥- មុខវិជ្ជាតម្រូវ(ពុំមានក្រេឌីត)**

| | | | |
|---|---|---|---|
| 1. | ១០២៤០៧ | តម្រង់ទិសការស្រាវជ្រាវ១(ប្រភេទ២) | S/U(៣-០-៩) |
| 2. | ១០២៤០៨ | តម្រង់ទិសការស្រាវជ្រាវ២(ប្រភេទ២) | S/U(៣-០-៩) |
| 3. | ១០២៤០៩ | តម្រង់ទិសការស្រាវជ្រាវ៣(ប្រភេទ២) | S/U(៣-០-៩) |
| 4. | ១០២២០២ | ភាសាអង់គ្លេសសម្រាប់ការអានកម្រិតខ្ពស់ | S/U(៣-០-៩) |
| 5. | ១០២២០៣ | ភាសាអង់គ្លេសសម្រាប់សំណេរកម្រិតខ្ពស់ | S/U(៣-០-៩) |

**២.៤.២.៦- ការសរសេរនិងការពារនិក្ខេបបទ(ចំនួន៣៣ក្រេឌីត)**

| | | | |
|---|---|---|---|
| 1. | ១០២៥៣១ | ការពារគម្រោងអត្ថបទស្រាវជ្រាវពិស្តារ | ៣ក្រេឌីត |
| 2. | ១០២៥៣២ | ការចុះផ្សាយអត្ថបទស្រាវជ្រាវកម្រិតជាតិឬកម្រិតអន្តរជាតិ | ៦ក្រេឌីត |
| 3. | ១០២៥៣៣ | ការចូលរួមវេទិកាវិទ្យាសាស្ត្រពាក់ព័ន្ធ | ៣ក្រេឌីត |
| 4. | ១០២៥៣៤ | ការធ្វើសិក្ខាសាលាផ្ទាល់ខ្លួន | ៣ក្រេឌីត |
| 5. | ១០២៤០៧ | និក្ខេបបទ១(ប្រភេទ២) | ៦ក្រេឌីត |
| 6. | ១០២៤០៨ | និក្ខេបបទ២(ប្រភេទ២) | ៦ក្រេឌីត |
| 7. | ១០២៤០៩ | និក្ខេបបទ៣(ប្រភេទ២) | ៦ក្រេឌីត |

**២.៤.២.៧- ការប្រឡងវាស់ស្ទង់គុណសម្បត្តិ(ការប្រឡងតម្រូវនិងពុំមានក្រេឌីត)**

| | | | |
|---|---|---|---|
| 1. | ១០២៥៥០ | ការប្រឡងវាស់ស្ទង់គុណសម្បត្តិ | S/U(៣-០-៩) |

ក្រៅពីមុខវិជ្ជាខាងលើនេះ អ្នកសិក្សាអាចចុះឈ្មោះចូលរៀនមុខវិជ្ជាផ្សេងទៀតបាន ដែលបើកបណ្តុះបណ្តាលដោយវិទ្យាស្ថានជាតិអប់រំ ដោយមានការឯកភាពពីគ្រូណែនាំឬគ្រូទី ប្រឹក្សានិងគណៈកម្មការគ្រប់គ្រងកម្មវិធីសិក្សា។

## ២.៥- ការប្រឡងវាស់ស្ទង់គុណសម្បត្តិ

- ការប្រឡងវាស់ស្ទង់គុណសម្បត្តិមិនមានក្រេឌីត និងជាការតម្រូវចាំបាច់សម្រាប់អ្នកសិក្សាថ្នាក់បណ្ឌិតអប់រំ

[4] មុខវិជ្ជានេះត្រូវបានផ្ទេរចេញពីក្រុមមុខវិជ្ជាថ្នាក់បណ្ឌិត មុខវិជ្ជាស្នូលនៃឯកទេស។ មុខវិជ្ជានេះ តម្រូវឱ្យនិស្សិតត្រូវចុះការងារជាក្រុមដើម្បីរៀបចំនិងផ្តល់ការ បណ្តុះបណ្តាលឬហ្វឹកហាត់ជាមួយសហគមន៍លើប្រធានបទអ្វីមួយ។

ជំនាញកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀន

- ការប្រឡងវាស់ស្ទង់គុណសម្បត្តិ ផ្តោតលើមុខវិជ្ជាកម្រិតបណ្ឌិតចំនួន៣មុខវិជ្ជា មុខវិជ្ជារួមចំនួន ១ មុខវិជ្ជា និងមុខវិជ្ជាស្នូលនៃឯកទេសចំនួន២មុខវិជ្ជា
- ការប្រឡងវាស់ស្ទង់គុណសម្បត្តិត្រូវធ្វើឡើងនៅមុនបំណាច់ធមាសទី១នៃឆ្នាំសិក្សាទី២ ឬបន្ទាប់ពីអ្នកសិក្សាបានសិក្សាយ៉ាងតិច១៨ក្រេឌីត។ ក្នុងករណីអ្នកសិក្សា ប្រឡងធ្លាក់ការប្រឡងវាស់ស្ទង់គុណសម្បត្តិ អ្នកសិក្សាអាចដាក់ពាក្យប្រឡងជាថ្មីរយៈពេល១ខែ ក្រោយថ្ងៃប្រកាសលទ្ធផល
- បន្ទាប់ពីប្រឡងជាប់ការប្រឡងវាស់ស្ទង់គុណសម្បត្តិ អ្នកសិក្សានឹងក្លាយជាបេក្ខជនថ្នាក់បណ្ឌិត[5]
- បន្ទាប់ពីនេះ អ្នកសិក្សាអាចស្នើប្រឡងការពារគម្រោងស្រាវជ្រាវបឋម[6] រួមមានសេចក្តីផ្តើម រំលឹកទ្រឹស្តី និងវិធីសាស្ត្រស្រាវជ្រាវ។ ក្រោយទទួលបានការអនុម័តគម្រោង ស្រាវជ្រាវបឋមពីគណៈកម្មការប្រឡងការពារនិក្ខេបបទ អ្នកសិក្សាមានពេលវេលាយ៉ាងតិច១៨ខែ សម្រាប់បញ្ចប់ការងារនិក្ខេបបទរបស់ខ្លួន។

## ២.៦- ផែនការដំណើរការកម្មវិធីសិក្សា

### ២.៦.១- ពេលវេលាដំណើរការកម្មវិធីសិក្សា

កិច្ចដំណើរការកម្មវិធីសិក្សាថ្នាក់បណ្ឌិតអប់រំ ជំនាញកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀន អាចរៀបចំឡើងជាថ្នាក់ពេញម៉ោងនិងក្រៅម៉ោង តាមពេលវេលាដូចខាងក្រោម៖

ប្រភេទថ្នាក់ពេញម៉ោង : រយៈពេល៣-៦ឆ្នាំ

ប្រភេទថ្នាក់ក្រៅម៉ោង : រយៈពេល៣-៨ឆ្នាំ

កម្មវិធីសិក្សាថ្នាក់បណ្ឌិតអប់រំ ជំនាញកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀន ជាកម្មវិធីដែលដំណើរការបង្រៀនចំនួន២ធមាសក្នុងមួយឆ្នាំសិក្សា។ ក្នុង១ធមាសមានរយៈពេលយ៉ាងតិច១៥សប្តាហ៍ដោយកំណត់កាលបរិច្ឆេទសិក្សាដូចខាងក្រោម៖

ធមាសទី១ : វិច្ឆិកា-កុម្ភៈ(អាចផ្លាស់ប្តូរតាមភាពជាក់ស្តែង)

ធមាសទី២ : មីនា-កក្កដា(អាចផ្លាស់ប្តូរតាមភាពជាក់ស្តែង)

វិស្សមកាលធំ : សីហា-តុលា(អាចផ្លាស់ប្តូរតាមភាពជាក់ស្តែង)

### ២.៦.២- ការចុះឈ្មោះរៀនក្នុងធមាស

| កម្មវិធីសិក្សាប្រភេទ១ | | | | |
|---|---|---|---|---|
| ឆ្នាំទី១ | | | | |
| ធមាស | លេខកូដ | មុខវិជ្ជា | ចំនួនក្រេឌីត | ប្រភេទមុខវិជ្ជា |
| ១ | ១០២៥០០ | និក្ខេបបទ១ | ៣ក្រេឌីត | |
| | ១០២៤០១ | តម្រង់ទិសការស្រាវជ្រាវ១(ប្រភេទ១) | S/U(៣-០-៩) | |
| ២ | ១០២៥០១ | និក្ខេបបទ២ | ៣ក្រេឌីត | |

[5] PhD Candidate

[6] Research Proposal

| | | | | |
|---|---|---|---|---|
| | ១០២៤០២ | តម្រង់ទិសការស្រាវជ្រាវ២(ប្រភេទ១) | S/U(៣-០-៩) | |
| **ឆ្នាំទី២** | | | | |
| **ឆមាស** | **លេខកូដ** | **មុខវិជ្ជា** | **ចំនួនក្រេឌីត** | **ប្រភេទមុខវិជ្ជា** |
| **១** | ១០២៥០២ | និក្ខេបបទ៣ | ៣ក្រេឌីត | |
| | ១០២៤០៣ | តម្រង់ទិសការស្រាវជ្រាវ៣(ប្រភេទ១) | S/U(៣-០-៩) | |
| **២** | ១០២៥៥០ | ប្រឡងវាស់ស្ទង់គុណសម្បត្តិ | S/U | |
| | ១០២៥០៣ | និក្ខេបបទ៤ | ៣ ក្រេឌីត | |
| | ១០២៤០៤ | តម្រង់ទិសការស្រាវជ្រាវ៤(ប្រភេទ១) | S/U(៣-០-៩) | |
| **ឆ្នាំទី៣** | | | | |
| **ឆមាស** | **លេខកូដ** | **មុខវិជ្ជា** | **ចំនួនក្រេឌីត** | **ប្រភេទមុខវិជ្ជា** |
| **១** | ១០២៥០៤ | និក្ខេបបទ៥ | ៣ក្រេឌីត | |
| | ១០២៤០៥ | តម្រង់ទិសការស្រាវជ្រាវ៥(ប្រភេទ១) | S/U(៣-០-៩) | |
| **២** | ១០២៥០៥ | និក្ខេបបទ៦ | ៣ក្រេឌីត | |
| | ១០២៤០៦ | តម្រង់ទិសការស្រាវជ្រាវ៦(ប្រភេទ១) | S/U(៣-០-៩) | |

| **កម្មវិធីសិក្សាប្រភេទ២** | | | | |
|---|---|---|---|---|
| **ឆ្នាំទី១** | | | | |
| **ឆមាស** | **លេខកូដ** | **មុខវិជ្ជា** | **ចំនួនក្រេឌីត** | **ប្រភេទមុខវិជ្ជា** |
| **១** | ១០២១០១ | ទ្រឹស្តីនិងនិន្នាការនៃការអប់រំ<br>Theory and Trends in Education | ២(២-០-៦) | មុខវិជ្ជាមូលដ្ឋានគ្រឹះបំពេញបន្ថែម |
| | ១០២១០២ | បរិបទនៃការអប់រំតាមបែបឌីជីថល<br>Contemporary of digital education | ២(២-០-៦) | មុខវិជ្ជាមូលដ្ឋានគ្រឹះបំពេញបន្ថែម |
| | ១០២១០៣ | ចិត្តវិទ្យាអប់រំ<br>Psychology of Education | ២(២-០-៦) | មុខវិជ្ជាមូលដ្ឋានគ្រឹះបំពេញបន្ថែម |
| | ១០២៤០៧ | តម្រង់ទិសការស្រាវជ្រាវ១(ប្រភេទ២) | S/U(៣-០-៩) | មុខវិជ្ជាតម្រូវ(ពុំមានក្រេឌីត) |
| **២** | ១០២២០១ | វិធីសាស្ត្រស្រាវជ្រាវអប់រំ | ៣(៣-០-៩) | មុខវិជ្ជាកម្រិតបណ្ឌិតរួមនៃឯកទេស |

| | | | | |
|---|---|---|---|---|
| | ១០២២៥១ | ការរៀបចំនិងអភិវឌ្ឍវិធីសាស្រ្តបង្រៀន Instructional System Development and Implementation | ៣(៣-០-៩) | មុខវិជ្ជាកម្រិតបណ្ឌិត ស្នូលនៃឯកទេស |
| | ១០២២៥២ | ការរៀបចំនិងអភិវឌ្ឍកម្មវិធីសិក្សា Advanced Curriculum and Implementation | ៣(៣-០-៩) | មុខវិជ្ជាកម្រិតបណ្ឌិត ស្នូលនៃឯកទេស |
| | ១០២២០២ | ភាសាអង់គ្លេសសម្រាប់ការអានកម្រិតខ្ពស់ Advanced English for Reading | S/U(៣-០-៩) | មុខវិជ្ជាតម្រូវ (ពុំមានក្រេឌីត) |
| | ១០២៤០៨ | តម្រង់ទិសការស្រាវជ្រាវ២ | S/U(៣-០-៩) | មុខវិជ្ជាតម្រូវ (ពុំមានក្រេឌីត) |
| **ឆ្នាំទី២** | | | | |
| **ឆមាស** | **លេខកូដ** | **មុខវិជ្ជា** | **ចំនួនក្រេឌីត** | **ប្រភេទមុខវិជ្ជា** |
| ១ | ១០២៣០១ | គំរូនៃការអនុវត្តកម្មវិធីសិក្សានិងវិធីសាស្រ្តបង្រៀន Implementation model of curriculum and instruction | ៣(៣-០-៩) | មុខវិជ្ជាតម្រង់ទិស |
| | ១០២៣០២ | ការអប់រំគ្រូនិងគុណភាពគ្រូបង្រៀន | ២(២-០-៦) | មុខវិជ្ជាតម្រង់ទិស |
| | ១០២៤០៩ | តម្រង់ទិសការស្រាវជ្រាវ៣ | S/U(៣-០-៩) | មុខវិជ្ជាតម្រូវ (ពុំមានក្រេឌីត) |
| | ១០២៤៩៩ | **ការប្រឡងវាស់ស្ទង់គុណសម្បត្តិ** Qualifying Exam បញ្ជាក់: ការប្រឡងវាស់ស្ទង់គុណសម្បត្តិ (Qualifying Exam) គឺជាការប្រឡងចាំបាច់សម្រាប់ក្លាយជាបេក្ខជនបណ្ឌិត។ ការប្រឡងនេះពុំផ្ដល់ក្រេឌីតទេ។ វិទ្យាស្ថានជាតិអប់រំ ត្រូវរៀបចំ គណៈកម្មការដើម្បីរៀបចំនិងវាយតម្លៃការប្រឡងវាស់ស្ទង់គុណសម្បត្តិ។ | S/U(៣-០-៩) | ការប្រឡងវាស់ស្ទង់គុណសម្បត្តិ |
| ២ | ១០២៣០៣ | ភាពបន្សុីគ្នានៃការអប់រំការច្នៃប្រឌិត | ២(២-០-៦) | មុខវិជ្ជាតម្រង់ទិស |
| | ១០២៣០៤ | ការវិភាគនិងការវាយតម្លៃលទ្ធផលរំពឹងទុកនៃ កម្មវិធីសិក្សា | ២(២-០-៦) | មុខវិជ្ជាតម្រង់ទិស |
| | ១០២២០៣ | ភាសាអង់គ្លេសសម្រាប់សំណេរកម្រិតខ្ពស់ | S/U(៣-០-៩) | មុខវិជ្ជាតម្រូវ (ពុំមានក្រេឌីត) |
| | ១០២៥២១ | និក្ខេបបទ១(ប្រភេទ២) | ៦ក្រេឌីត | និក្ខេបបទ |
| **ឆ្នាំទី ៣** | | | | |

| ឆមាស | លេខកូដ | មុខវិជ្ជា | ចំនួនក្រេឌីត | ប្រភេទមុខវិជ្ជា |
|---|---|---|---|---|
| **១** | ១០២៥២២ | និក្ខេបបទ២(ប្រភេទ២) | ៦ក្រេឌីត | និក្ខេបបទ |
| **២** | ១០២៥២៣ | និក្ខេបបទ៣(ប្រភេទ២) | ៦ក្រេឌីត | និក្ខេបបទ |

# ជំពូកទី៣៖
# សាស្ត្រាចារ្យ គម្រោងស្រាវជ្រាវ និក្ខេបបទ និងការវាយតម្លៃ

## ៣.១- សាស្ត្រាចារ្យបង្រៀនមុខវិជ្ជា

សាស្ត្រាចារ្យដែលត្រូវបង្រៀនថ្នាក់បណ្ឌិតអប់រំ ជំនាញកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀន ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

- មានសញ្ញាបត្របណ្ឌិតលើជំនាញអប់រំឬជំនាញសមស្រប ឬបទពិសោធគ្រប់គ្រាន់ពាក់ព័ន្ធនឹងមុខវិជ្ជាដែលខ្លួនទទួលបន្ទុកបង្រៀន ហើយមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា
- មានសមត្ថភាពក្នុងការប្រើប្រាស់ភាសាបរទេសនិងបច្ចេកវិទ្យាព័ត៌មាន
- មានចរិយាសម្បត្តិ សីលធម៌ មនសិការវិជ្ជាជីវៈ និងមានភាពជាគ្រូបង្រៀន។

## ៣.២- សាស្ត្រាចារ្យណែនាំគោលនិងសាស្ត្រាចារ្យណែនាំរង

សាស្ត្រាចារ្យណែនាំត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

- មានសញ្ញាបត្របណ្ឌិតនិងមានបទពិសោធការងារស្រាវជ្រាវយ៉ាងតិច៣ឆ្នាំ
- មានស្នាដៃនិងកិត្តិនាមក្នុងការចុះផ្សាយអត្ថបទស្រាវជ្រាវវិទ្យាសាស្ត្រជាតិនិងអន្តរជាតិ
- មានស្មារតីទទួលខុសត្រូវក្នុងការណែនាំការស្រាវជ្រាវវិទ្យាសាស្ត្រ
- មានសមត្ថភាពក្នុងការប្រើប្រាស់ភាសាបរទេសនិងបច្ចេកវិទ្យាព័ត៌មាន
- មានចរិយាសម្បត្តិ សីលធម៌ មនសិការវិជ្ជាជីវៈ និងមានភាពជាគ្រូបង្រៀន។

សាស្ត្រាចារ្យណែនាំគោលនិងសាស្ត្រាចារ្យណែនាំរង ត្រូវមានការទទួលខុសត្រូវ៖

- សម្របសម្រួលការពារគម្រោងអត្ថបទស្រាវជ្រាវពិស្តាររបស់អ្នកសិក្សា
- ត្រួតពិនិត្យនិងសម្របសម្រួលការចុះផ្សាយអត្ថបទស្រាវជ្រាវកម្រិតជាតិឬកម្រិតអន្តរជាតិរបស់អ្នកសិក្សា
- សម្របសម្រួលការចូលរួមវេទិកាវិទ្យាសាស្ត្រពាក់ព័ន្ធរបស់អ្នកសិក្សា
- សម្របសម្រួលការធ្វើសិក្ខាសាលាផ្ទាល់ខ្លួនរបស់អ្នកសិក្សា
- ដឹកនាំនិងពិនិត្យដំណើរការសរសេរនិក្ខេបបទរបស់អ្នកសិក្សា

## ៣.៣- ការស្នើគម្រោងស្រាវជ្រាវសរសេរនិក្ខេបបទ

កម្មវិធីសិក្សាថ្នាក់បណ្ឌិតអប់រំ ជំនាញកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀន តម្រូវឱ្យអ្នកសិក្សាដែលចុះឈ្មោះរៀនក្នុងកម្មវិធីទាំងប្រភេទទី១និងប្រភេទទី២ សរសេរនិក្ខេបបទ ដើម្បីបញ្ចប់ការសិក្សាដោយផ្អែកលើលក្ខខណ្ឌកំណត់ដោយកម្មវិធីសិក្សានៃវិទ្យាស្ថានជាតិអប់រំ។

### ៣.៣.១- លក្ខណៈសម្បត្តិសម្រាប់ការស្រាវជ្រាវសរសេរនិក្ខេបបទ

ដើម្បីស្នើគម្រោងស្រាវជ្រាវសរសេរនិក្ខេបបទបាន អ្នកសិក្សាត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

- មានចំណេះដឹងស៊ីជម្រៅលើផ្នែកគ្រប់គ្រងអប់រំ
- មានវិធីសាស្ត្រធ្វើការងារស្រាវជ្រាវបានយ៉ាងល្អ

- មានសីលធម៌វិជ្ជាជីវៈក្នុងការងារស្រាវជ្រាវ
- មានសមត្ថភាពគិត វិភាគ និងដោះស្រាយបញ្ហាដែលកើតឡើងក្នុងការងារស្រាវជ្រាវដោយឯករាជ្យ
- មានសមត្ថភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យា ភាសាជាតិ និងភាសាបរទេសដើម្បីស្វែងរកព័ត៌មានសម្រាប់គាំទ្រការងារស្រាវជ្រាវ
- មានសុខភាពបរិបូរណ៍ អាចបំពេញការងារបានប្រកបដោយប្រសិទ្ធភាពក្នុងកំលុងពេលធ្វើការងារស្រាវជ្រាវសរសេរនិក្ខេបបទ។

**៣.៣.២- រយៈពេល**

អ្នកសិក្សាចុះឈ្មោះរៀនក្នុងកម្មវិធីសិក្សាទាំង២ប្រភេទ ត្រូវស្នើគម្រោងស្រាវជ្រាវសរសេរនិក្ខេបបទយ៉ាងយូរមុនដំណាច់ឆ្នាំសិក្សាទី២។ គម្រោងស្រាវជ្រាវសរសេរនិក្ខេបបទ ត្រូវទទួលបានការអនុម័តពីគណៈកម្មការយ៉ាងយូរបំផុតមិនឱ្យលើសឆមាសទី២នៃឆ្នាំទី៣។

**៣.៣.៣- ចំនួនក្រេឌីតការងារស្រាវជ្រាវ( និក្ខេបបទ )**

កម្មវិធីសិក្សាប្រភេទ១ មានចំនួន១៨ក្រេឌីត

កម្មវិធីសិក្សាប្រភេទ២ មានចំនួន១៨ក្រេឌីត

**៣.៣.៤- ការត្រៀម**

ដើម្បីឱ្យកិច្ចដំណើរការអនុវត្តកម្មវិធីសិក្សាថ្នាក់បណ្ឌិតអប់រំ ជំនាញកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀនទទួលបានលទ្ធផលល្អប្រសើរ គណៈកម្មការគ្រប់គ្រងកម្មវិធីសិក្សាត្រូវត្រៀមលក្ខណៈដូចខាងក្រោម៖

- តែងតាំងឬចាត់តាំងសាស្ត្រាចារ្យណែនាំគោលនិងសាស្ត្រាចារ្យណែនាំរង សម្រាប់ដឹកនាំអ្នកសិក្សាស្រាវជ្រាវសរសេរនិក្ខេបបទ
- ក្នុងឆមាសនីមួយៗ អ្នកសិក្សាត្រូវចុះឈ្មោះចូលរៀនមុខវិជ្ជាសិក្ខាសាលានិក្ខេបបទថ្នាក់បណ្ឌិត។ លក្ខខណ្ឌនៃកម្មវិធីសិក្សាតម្រូវឱ្យនិស្សិតស្នើគម្រោងស្រាវជ្រាវសរសេរនិក្ខេបបទ និងរាយការណ៍អំពីវឌ្ឍនភាពការស្រាវ ជ្រាវជារៀងរាល់ឆមាស ដើម្បីពិនិត្យតាមដានការធ្វើការងាររបស់អ្នកសិក្សានិងដើម្បីធានាបានអ្នកសិក្សាអាចបញ្ចប់ការសិក្សាតាមកាលបរិច្ឆេទសិក្សាបានកំណត់។

## ៣.៤- ការវាយតម្លៃការសិក្សា

ការវាយតម្លៃកាសិក្សាទូទៅនិងការប្រឡងការពារនិក្ខេបបទ ត្រូវអនុវត្តតាមលក្ខខណ្ឌរបស់វិទ្យាស្ថានជាតិអប់រំដែលបានកំណត់ដោយផ្អែកលើសេចក្ដីណែនាំចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ របស់ក្រសួងអប់រំ យុវជន និងកីឡា។

## ៣.៥- ចំណាត់ថ្នាក់ពិន្ទុ

| ពិន្ទុតាមកម្រិត | សមាសភាគភាគរយ | សញ្ញាពិន្ទុជាអក្សរ | ការបរិយាយ |
|---|---|---|---|
| ៤.00 | ៨៥-១00 | A | ល្អប្រសើរ |
| ៣.៥0 | ៨0-៨៤ | B+ | ល្អណាស់ |
| ៣.00 | ៧0-៧៩ | B | ល្អ |

| | | | |
|---|---|---|---|
| ២.៥០ | ៦៥-៦៩ | C+ | ល្អបង្គួរ |
| ២.០០ | ៥០-៦៤ | C | មធ្យម |
| ១.៥០ | ៤៥-៤៩ | D+ | ខ្សោយ |
| ១.០០ | ៤០-៤៤ | D | ខ្សោយណាស់ |
| ០.០០ | ០-៣៩ | F | ធ្លាក់ |
| បញ្ជាក់ : និស្សិតថ្នាក់បណ្ឌិត ត្រូវទទួលបានមធ្យមភាគពិន្ទុសរុបយ៉ាងតិចបំផុតត្រឹម៣.០០ (ក្នុងប្រព័ន្ធ ៤.០០) ឬ និទ្ទេសB។ | | | |

## ៣.៦- លទ្ធផលនៃការសិក្សា វិធីសាស្ត្របង្រៀន និងវិធីសាស្ត្រវាយតម្លៃ

| | លទ្ធផលនៃការសិក្សា | វិធីសាស្ត្របង្រៀន | វិធីសាស្ត្រវាយតម្លៃ |
|---|---|---|---|
| ១- ចំណេះដឹង | យល់ដឹងអំពីចំណុចសំខាន់ៗស្តីពីកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន រួមមានទស្សនវិជ្ជា ចិត្តវិទ្យា ទ្រឹស្តី គោលការណ៍ និងទស្សនាទាននៃកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀន ជាមូលដ្ឋានគ្រប់កម្រិតថ្នាក់។<br>យល់ដឹងច្បាស់ពីទស្សនវិជ្ជាអប់រំ ចិត្តវិទ្យាអប់រំ ប្រវត្តិអប់រំ ច្បាប់អប់រំ មូលដ្ឋានសង្គមនៃការអប់រំ និងការវិវត្តចុងក្រោយនៃការអប់រំ ជាពិសេសផ្នែកកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀន នៅគ្រប់កម្រិតថ្នាក់។<br>យល់ដឹងពីការអភិវឌ្ឍជំនាញកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀនដែលមានឥទ្ធិពលទៅលើការអនុវត្តវិជ្ជាជីវៈក្នុងវិស័យអប់រំ។ | បង្រៀនដោយវិធី Lecture, Seminar, Critical Analysis, Synthesis, Problem-Based, Research-Based, Self-Directed Learning | ការប្រឡង ការធ្វើតេស្ត<br>ការត្រួតពិនិត្យស្នាដៃលទ្ធផលការងារ<br>ការត្រួតពិនិត្យលើការធ្វើបទបង្ហាញ |
| ២- ជំនាញការគិតវិភាគ | ស្រាវជ្រាវលើការងារផ្នែកកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀន ដើម្បីបង្កើតចំណេះដឹងថ្មីៗ និងដោះស្រាយបញ្ហាផ្សេងៗក្នុងការងារអភិវឌ្ឍ អនុវត្ត និងវាយតម្លៃកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀនគ្រប់កម្រិតថ្នាក់ប្រកប ដោយគំនិតច្នៃប្រឌិតនិងនិរន្តរភាព តាមរយៈការសិក្សាពេញមួយជីវិត។ វិភាគនិងសំយោគទ្រឹស្តី ទស្សនាទាន យុទ្ធសាស្ត្រ និងគោលនយោបាយនានាមកជាកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀនសម្រាប់អនុវត្តក្នុងវិស័យអប់រំគ្រប់កម្រិតសិក្សាប្រកបដោយភាពទន់ភ្លន់និងប្រសិទ្ធភាពខ្ពស់ស្របតាមទិសដៅអប់រំជាតិ តំបន់ និងសកល។ | បង្រៀនដោយផ្តោតលើការអនុវត្តដែលប្រើប្រាស់ Case Study, Seminar, Critical Analysis, Synthesis, Problem-Based, Research-Based, Self-Directed, Lecture, Project-based | ការសង្កេតឥរិយាបទចំពោះការសិក្សានិងការងារដែលខ្លួនទទួលខុសត្រូវ<br>ការពិនិត្យដោះស្រាយបញ្ហាក្នុងស្ថានភាពជាក់ស្តែង<br>ការត្រួតពិនិត្យលើការធ្វើបទបង្ហាញ |

| | លទ្ធផលនៃការសិក្សា | វិធីសាស្ត្របង្រៀន | វិធីសាស្ត្រវាយតម្លៃ |
|---|---|---|---|
| ៣- ជំនាញទំនាក់ទំនងអន្តរបុគ្គល និងការទទួលខុសត្រូវ | ប្រព្រឹត្តយ៉ាងសមស្របប្រកបដោយស្វ័យភាព និងការផ្តួចផ្តើមគំនិតកម្រិតខ្ពស់ក្នុងសកម្មភាពទាក់ទងការរៀបចំកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀន។<br>សម្របសម្រួលនិងលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងការធ្វើការងារជាក្រុម និងអនុវត្តយ៉ាងមានប្រសិទ្ធភាពក្នុងភាពជាអ្នកដឹកនាំក្នុងវិជ្ជាជីវៈផ្នែកកម្មវិធី សិក្សានិងវិធីសាស្ត្របង្រៀនដ៏ស្មុគស្មាញ។ស្រាវជ្រាវនិងស្វែងរកឫសគល់នៃបញ្ហាទាក់ទងនឹងកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀនដើម្បីរកដំណោះស្រាយប្រកបដោយសុភវិនិច្ឆ័យ ដោយឈរលើប្រយោជន៍រួមជាមូលដ្ឋាន។ | បង្រៀនដោយរៀបចំសកម្មភាពបង្រៀនបង្កលក្ខណៈឱ្យនិស្សិតធ្វើការជាក្រុម និងជាបុគ្គល | ការសង្កេតឥរិយាបទ ការចូលរួមការងារក្នុងក្រុម និងការធ្វើការងារដែលខ្លួនទទួលខុសត្រូវ |
| ៤- ជំនាញលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង | មានបំណិនក្នុងការប្រើប្រាស់ភាសានិងបច្ចេកវិទ្យាក្នុងការងារទំនាក់ទំនង ការស្វែងរកព័ត៌មានផ្នែកកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន ការរៀបចំសិក្ខាសាលា ការរៀបចំគម្រោង ការសរសេររបាយការណ៍ ការធ្វើបទបង្ហាញផ្លូវការនិងមិនផ្លូវការ ការបោះពុម្ពផ្សាយក្នុងទម្រង់ជានិក្ខេបបទជំនាញ ឬរបាយការណ៍គម្រោងស្តីអំពីបញ្ហាសំខាន់និងស្មុគស្មាញណាមួយប្រកបដោយតម្លាភាពនិងការទទួលខុសត្រូវខ្ពស់។ប្រើប្រាស់និងវិភាគយ៉ាងមានប្រសិទ្ធភាពនូវព័ត៌មាន ទិន្នន័យ គណិតវិទ្យានិងស្ថិតិ ។ | បង្រៀនដោយប្រើប្រាស់បច្ចេកវិទ្យាក្នុងការស្វែងរកឯកសារ ការវិភាគសំយោគទិន្នន័យទាំងបែបគុណភាព និងបែបបរិមាណ ការធ្វើការជាក្រុម ការធ្វើបទបង្ហាញមតិយោបល់ និងលទ្ធផលការងារ។ | ពិនិត្យលើលទ្ធផលការងារដែលខ្លួនទទួលខុសត្រូវដូចជាWorking Paper, Project ជាដើម។<br>សង្កេតការធ្វើការជាក្រុម<br>ពិនិត្យលើសមត្ថភាពការប្រើប្រាស់បច្ចេកវិទ្យាដើម្បីស្វែងរកចំណេះដឹងនិងគ្រប់គ្រងប្រព័ន្ធទិន្នន័យ។ |

# ជំពូកទី៤៖
# ពណ៌នាមុខវិជ្ជា[7]

## ៤.១ ការពិពណ៌នាមុខវិជ្ជា

### ៤.១.១- មុខវិជ្ជាមូលដ្ឋានគ្រឹះបំពេញបន្ថែម

1. **១០២១០១** **ទ្រឹស្តីនិងនិន្នាការនៃការអប់រំ**
   Theory and Trends in education ២(២-០-៦)
2. **១០២១០២** **បរិបទនៃការអប់រំតាមបែបឌីជីថល**
   Contemporary of digital education ២(២-០-៦)
3. **១០២១០៣** **ចិត្តវិទ្យាអប់រំ** Psychology of Education ២(២-០-៦)

### ៤.១.២- មុខវិជ្ជាកម្រិតបណ្ឌិត រួមនៃឯកទេស

1. **១០២២០១** **វិធីសាស្ត្រស្រាវជ្រាវអប់រំ** ៣(៣-០-៩)
   ទស្សនវិជ្ជានៃការស្រាវជ្រាវអប់រំ ការពិនិត្យឡើងវិញនៃអក្សរសិល្ប៍ដែលពាក់ព័ន្ធ (literature review) ក្របខ័ណ្ឌគោលគំនិតនៃការស្រាវជ្រាវ គោលការណ៍ការរៀបចំស្រាវជ្រាវ វិធីសាស្ត្រស្រាវជ្រាវ ការអភិវឌ្ឍសំណើគម្រោងបឋមនៃការស្រាវជ្រាវ ការរៀបចំនិងការសរសេររបាយការណ៍ ការវាយតម្លៃនិងការរិះគន់លើការស្រាវជ្រាវ ការផ្សព្វផ្សាយ និងក្រមសីលធម៌ គោលការណ៍និងការរចនានៃការស្រាវជ្រាវគុណភាព(Qualitative research) ការស្រាវជ្រាវបរិមាណ(Quantitative research) និងការស្រាវជ្រាវវិធីសាស្ត្រចម្រុះ (Mix-Method research) សម្រាប់ការអភិវឌ្ឍផ្នែកអប់រំ ការស្រាវជ្រាវឯកសារ ការគ្រប់គ្រងការស្រាវជ្រាវ ការវាយតម្លៃនិងការប្រើប្រាស់ ការផ្សព្វផ្សាយអំពីថ្នាក់ជាតិនិងអន្តរជាតិ។
2. **១០២២០២**[8] **ភាសាអង់គ្លេសសម្រាប់អំណានកម្រិតខ្ពស់**
   Advanced English for Reading S/U(៣-០-៩)
3. **១០២២០៣**[9] **ភាសាអង់គ្លេសសម្រាប់សំណេរកម្រិតខ្ពស់**
   Advanced English for Writing S/U(៣-០-៩)

### ៤.១.៣- មុខវិជ្ជាកម្រិតបណ្ឌិត ស្នូលនៃឯកទេស

4. **១០២២៥១** **ការរៀបចំនិងអភិវឌ្ឍវិធីសាស្ត្របង្រៀន**
   Instructional System Development and Implementation ៣(៣-០-៩)

---

[7] ពណ៌នាមុខវិជ្ជានេះ សម្រាប់ការចុះឈ្មោះចូលរៀនកម្មវិធីប្រភេទ១ នៃក្របខណ្ឌកម្មវិធីសិក្សាថ្នាក់បណ្ឌិតអប់រំ ជំនាញកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀន សម្រាប់ការអនុវត្តសាកល្បង(Try Out)។ សម្រាប់ការអនុវត្តផ្លូវការនៃក្របខណ្ឌនៃកម្មវិធីសិក្សានេះ វិទ្យាស្ថានជាតិអប់រំមានលទ្ធភាពក្នុងការរៀបចំពណ៌នាមុខវិជ្ជាតាមការចាំបាច់។

[8] សិក្សារួមជាមួយមុខវិជ្ជា ភាសាអង់គ្លេសសម្រាប់អំណានកម្រិតខ្ពស់(Advanced English for Reading) (១០១២០១) S/U(៣-០-៩) ថ្នាក់បណ្ឌិតអប់រំ ជំនាញគ្រប់គ្រងអប់រំ។

[9] សិក្សារួមជាមួយមុខជ្ជា ភាសាអង់គ្លេសសម្រាប់សំណេរកម្រិតខ្ពស់(Advanced English for Writing) (១០១២០១) S/U(៣-០-៩) ថ្នាក់បណ្ឌិតអប់រំ ជំនាញគ្រប់គ្រងអប់រំ។

គំនិតសំខាន់ៗក្នុងការបង្រៀននិងទំនាក់ទំនងនៃគំនិត ទ្រឹស្តីនិងគោលការណ៍បង្រៀន ម៉ូដែល វិធីសាស្ត្រនិងបច្ចេកទេសនៃការបង្រៀន ដំណើរការក្នុងការអភិវឌ្ឍនិងគំរូប្រព័ន្ធអប់រំ ការសិក្សាស៊ីជម្រៅលើប្រព័ន្ធបង្រៀននិង ម៉ូដែលផ្សេងៗ អភិវឌ្ឍនិងសាកល្បងប្រព័ន្ធឬម៉ូដែលបង្រៀន ការស្រាវជ្រាវពាក់ព័ន្ធការវាយតម្លៃនិងការកែលម្អវិធី សាស្ត្របង្រៀន។

5. **១០២២៥២ ការរៀបចំនិងអភិវឌ្ឍកម្មវិធីសិក្សា**

Advanced Curriculum and Implementation ៣(៣-០-៩)

ការសិក្សាស៊ីជម្រៅអំពីទ្រឹស្តីនិងគោលការណ៍នៃការអភិវឌ្ឍកម្មវិធីសិក្សានិងវិស្វកម្មកម្មវិធីសិក្សា (cirriculum engineering) រៀបចំផែនការកម្មវិធីសិក្សា ការអនុវត្តកម្មវិធីសិក្សា និងវាយតម្លៃកម្មវិធីសិក្សា ការកែលម្អកម្មវិធីសិក្សា(curriculum improvement) ការអភិវឌ្ឍកម្មវិធីសិក្សាក្នុងស្រុក ការផលិតសម្ភារៈឧបទ្ទេស ការស្រាវជ្រាវសម្រាប់ការអភិវឌ្ឍកម្មវិធីសិក្សា គោលគំនិតនិងការណែនាំពីបច្ចុប្បន្នភាពនៃកម្មវិធីសិក្សា បញ្ហាបច្ចុប្បន្ននិងនិន្នាការក្នុងការអភិវឌ្ឍកម្មវិធីសិក្សានិងការអនុវត្តកម្មវិធីសិក្សាតាមគ្រឹះស្ថានសិក្សាគ្រប់កម្រិត។

### ៤.១.៤- មុខវិជ្ជាតម្រង់ទិសនិងការប្រឡងទូទៅ

1. **១០២៣០១ គំរូនៃការអនុវត្តកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀន**

Implementation model of curriculum and instruction ៣(៣-០-៩)

សំយោគមេរៀន គោលការណ៍ និងចំណេះដឹងផ្នែកកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀន តាមរយៈការហ្វឹកហាត់ជាក់ស្តែង អនុវត្តការអភិវឌ្ឍកម្មវិធីសិក្សា ការអនុវត្តកម្មវិធីសិក្សា និងការវាយតម្លៃកម្មវិធីសិក្សានៅក្នុងវិទ្យាស្ថានជាតិអប់រំនិងអង្គការនានា។

2. **១០២៣០២ ការអប់រំគ្រូនិងគុណភាពគ្រូបង្រៀន** ២(២-០-៦)
3. **១០២៣០៣ ភាពបន្សុីគ្នានៃការអប់រំការច្នៃប្រឌិត** ២(២-០-៦)
4. **១០២៣០៤ ការវិភាគនិងការវាយតម្លៃលទ្ធផលរំពឹងទុកនៃកម្មវិធីសិក្សា** ២(២-០-៦)

### ៤.១.៥- មុខវិជ្ជាតម្រូវ(ពុំផ្តល់ក្រេឌីត)

1. **១០២៤០៧ តម្រង់ទិសការស្រាវជ្រាវ១(ប្រភេទ២)** S/U(៣-០-៩)
2. **១០២៤០៨ តម្រង់ទិសការស្រាវជ្រាវ២(ប្រភេទ២)** S/U(៣-០-៩)
3. **១០២៤០៩ តម្រង់ទិសការស្រាវជ្រាវ៣(ប្រភេទ២)** S/U(៣-០-៩)

### ៤.១.៦- ការប្រឡងវាស់ស្ទង់គុណសម្បត្តិ

1. **១០២៤៩៩ ការប្រឡងវាស់ស្ទង់គុណសម្បត្តិ** S/U(៣-០-៩)

### ៤.១.៧- និក្ខេបទ

1. **១០២៥០១ និក្ខេបបទ១(ប្រភេទ១)** ៣ក្រេឌីត

ជំហានដំបូងនៃការងារស្រាវជ្រាវដោយសិក្សាលើការរំលឹកទ្រឹស្តីទាក់ទងនឹងការគ្រប់គ្រងអប់រំ ការកំណត់ប្រធានបទនៃការងារស្រាវជ្រាវ ក្របខ័ណ្ឌនៃការងារស្រាវជ្រាវ(Conceptual Framework and Conceptual Innovation)។

2. **១០២៥០២ និក្ខេបបទ២(ប្រភេទ១) ៣ក្រេឌីត**
ការស្នើសេចក្តីព្រាងនៃគម្រោងស្រាវជ្រាវបឋម ជូនគណៈកម្មការត្រួតពិនិត្យនិងកែលម្អតាមការណែនាំរបស់គណៈកម្មការ។
3. **១០២៥០៣ និក្ខេបបទ៣(ប្រភេទ១) ៣ក្រេឌីត**
ការស្នើការពារគម្រោងស្រាវជ្រាវ (Submit draft of the proposal, present the research proposal to the committee members)។
4. **១០២៥០៤ និក្ខេបបទ៤(ប្រភេទ១) ៣ក្រេឌីត**
ដំណើរការកសាងឧបករណ៍ប្រមូលទិន្នន័យការវាយតម្លៃសុពលភាពពីអ្នកជំនាញ(Validity Check) និងការធ្វើតេស្តសាកល្បងឧបករណ៍ប្រមូលទិន្នន័យ(Reliability Check)។
5. **១០២៥០៥ និក្ខេបប៥(ប្រភេទ១) ៣ក្រេឌីត**
ការប្រមូលទិន្នន័យ(Data Collection) ការបញ្ចូលទិន្នន័យ(Data Entry) ការដំណើរការសម្អាតទិន្នន័យ(Data Processing and Cleaning) ការវិភាគទិន្នន័យ(Data Analysis) និងការបកស្រាយទិន្នន័យ(Data Interpretation)។
6. **១០២៥០៦ និក្ខេបបទ៦(ប្រភេទ១) ៣ក្រេឌីត**
ការសរសេររបាយការណ៍ការស្រាវជ្រាវ (និក្ខេបបទ) ស្នើប្រឡងការពារនិក្ខេបបទផ្ទាល់មាត់ និងបោះពុម្ព។
7. **១០២៥២១ និក្ខេបបទ១(ប្រភេទ២) ៦ក្រេឌីត**
ជំហានដំបូងនៃការងារស្រាវជ្រាវដោយសិក្សាលើការរំលឹកទ្រឹស្តីទាក់ទងនឹងការគ្រប់គ្រងអប់រំ ការកំណត់ប្រធានបទនៃការងារស្រាវជ្រាវ ក្របខ័ណ្ឌនៃការងារស្រាវជ្រាវ(Conceptual Framework and Conceptual Innovation)។ ស្នើសេចក្តីព្រាងនៃគម្រោងស្រាវជ្រាវបឋមជូនគណៈកម្មការត្រួតពិនិត្យនិងកែលម្អតាមការណែនាំរបស់គណៈកម្មការ និងស្នើការពារគម្រោងស្រាវជ្រាវ។
8. **១០២៥២២ និក្ខេបបទ២(ប្រភេទ២) ៦ក្រេឌីត**
ការប្រមូលទិន្នន័យ(Data Collection) ការបញ្ចូលទិន្នន័យ(Data Entry) ការដំណើការសម្អាតទិន្នន័យ(Data Processing and Cleaning) ការវិភាគទិន្នន័យ(Data Analysis) និងការបកស្រាយទិន្នន័យ(Data Interpretation)។
9. **១០២៥២៣ និក្ខេបបទ៣(ប្រភេទ២) ៦ក្រេឌីត**
ការសរសេររបាយការណ៍ការស្រាវជ្រាវ(និក្ខេបបទ) ស្នើប្រឡងការពារនិក្ខេបបទផ្ទាល់មាត់និងបោះពុម្ព។
10. **១០២៥៣១ ការពារគម្រោងអត្ថបទស្រាវជ្រាវពិស្តារ ៣ក្រេឌីត**
11. **១០២៥៣២**[10] **ការចុះផ្សាយអត្ថបទស្រាវជ្រាវកម្រិតជាតិឬកម្រិតអន្តរជាតិ ៦ក្រេឌីត**
ចុះផ្សាយអត្ថបទស្រាវជ្រាវចំនួន២អត្ថបទក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រកម្រិតជាតិនិងអន្តរជាតិដែលមានបណ្ណាធិការ និងអ្នកត្រួតពិនិត្យឯករាជ្យថ្នាក់ជាតិឬអន្តរជាតិ។
12. **១០២៥៣៣ ការចូលរួមវេទិកាវិទ្យាសាស្ត្រពាក់ព័ន្ធ ៣ក្រេឌីត**
ធ្វើបទបង្ហាញអត្ថបទស្រាវជ្រាវដែលត្រូវចុះផ្សាយក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រនៅក្នុងវេទិកាវិទ្យាសាស្ត្រជាតិនិងអន្តរជាតិ ដែលមានលក្ខណៈ Conference Proceedings ចំនួនយ៉ាងតិច១ដង។

---

[10] ការចុះផ្សាយអត្ថបទស្រាវជ្រាវកម្រិតជាតិឬកម្រិតអន្តរជាតិ មានចំនួន១២ក្រេឌីតសម្រាប់ការចុះឈ្មោះចូលរៀនកម្មវិធីសិក្សាប្រភេទ១ និងចំនួន៦ក្រេឌីតសម្រាប់ការចុះឈ្មោះចូលរៀនកម្មវិធីសិក្សាប្រភេទ២។

13. **១០២៥៣៤ ការធ្វើសិក្ខាសាលាផ្ទាល់ខ្លួន ៣ក្រេឌីត**

ការធ្វើសិក្ខាសាលាផ្ទាល់ខ្លួន គឺជាការឡើងធ្វើបទបង្ហាញនូវលទ្ធផល និងចំណេះដឹងដែលបានមកពីការស្រាវជ្រាវរបស់ខ្លួនដែលត្រូវធ្វើចំនួន២ដង ដើម្បីស្វែងរកភាពចន្លោះប្រហោងនិងចំណុចខ្សោយរបស់និក្ខេបបទ តាមរយៈការរិះគន់ សំណួរនិងការបកស្រាយ និងអនុសាសន៍ពីក្រុមអ្នកជំនាញពាក់ព័ន្ធ សំដៅធ្វើឱ្យនិក្ខេបបទកាន់តែមានភាពសុក្រិត និងឆ្ពោះទៅរកការបញ្ចប់ដោយជោគជ័យ។សិក្ខាសាលានីមួយៗត្រូវរៀបចំដោយគណៈកម្មការគ្រប់គ្រងកម្មវិធីសិក្សា។

# ឯកសារយោង៖

1- យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា ខែកញ្ញា ឆ្នាំ ២០១៨។
2- ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា ខែមីនា ឆ្នាំ២០១៤។
3- សេចក្តីណែនាំលម្អិតស្តីពីការបណ្តុះបណ្តាលថ្នាក់បណ្ឌិត ឆ្នាំ២០១២។
4- ក្របខ័ណ្ឌកម្មវិធីសិក្សាថ្នាក់បណ្ឌិតអប់រំ ជំនាញកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀន សាកលវិទ្យាល័យ ជុំឡាទ្បុងកន ឆ្នាំ២០១៨។

## ឧបសម្ព័ន្ធ៖ អត្ថន័យលេខកូដមុខវិជ្ជា

XXX XXX

លេខកូដថ្នាក់បណ្ឌិត ជំនាញ | លេខកូដមុខវិជ្ជា

| ល.រ. | បណ្ឌិតអប់រំ ជំនាញ | លេខកូដ៣ខ្ទង់មុខ |
|---|---|---|
| ១- | បណ្ឌិតអប់រំ ជំនាញកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀន | ១០២ XXX |

| ល.រ. | ឈ្មោះក្រុមមុខវិជ្ជា | លេខកូដ៣ខ្ទង់ក្រោយ |
|---|---|---|
| ១- | មុខវិជ្ជាមូលដ្ឋានគ្រឹះបំពេញបន្ថែម | XXX (១០០ដល់១៩៩) |
| ២- | មុខវិជ្ជាកម្រិតបណ្ឌិត | XXX (២០០ដល់២៩៩) |
| ៣- | មុខវិជ្ជាកម្រិតបណ្ឌិត(មុខវិជ្ជារួមនៃឯកទេស) | XXX (២០០ដល់២៤៩) |
| ៤- | មុខវិជ្ជាកម្រិតបណ្ឌិត(មុខវិជ្ជាស្នូលនៃឯកទេស) | XXX (២៥០ដល់២៩៩) |
| ៥- | មុខវិជ្ជាតម្រង់ទិសនិងការប្រឡងទូទៅ | XXX (៣០០ដល់៣៩៩) |
| ៤- | មុខវិជ្ជាតម្រូវ(ពុំផ្តល់ក្រេឌីត) | XXX (៤០០ដល់៤៩៨) |
| ៥- | ការប្រឡងវាស់ស្ទង់គុណសម្បត្តិ | XXX ៤៩៩ |
| ៦- | និក្ខេបបទ | XXX (៥០០ដល់៥៩៩) |
| | ៦.១- និក្ខេបបទប្រភេទ១ | XXX (៥០០ដល់៥១៩) |
| | ៦.២- និក្ខេបបទប្រភេទ២ | XXX (៥២០ដល់៥២៩) |
| | ៦.៣- ផ្សេងៗ | XXX (៥៣០ដល់៥៩៩) |